អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន

# សហចៅក្រមស៊ើបអង្កេត លើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម

នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកា ដំណោះស្រាយរួមគ្នានៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម នៅក្នុងសំណុំរឿង 00៤/១។

សហចៅក្រមស៊ើបអង្កេត បានលើកលែងការចោទប្រកាន់សំណុំរឿងនេះ ដោយសារថា តាមរយៈការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតលើភស្តុតាងដែលប្រមូលបាននៅក្នុងអំឡុងពេលស៊ើបសួរ អ៊ឹម ចែម មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ។ នេះមានន័យថា អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬក៏ជាជនម្នាក់ក្នុងចំណោមមន្ត្រីដែលទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងរបបខ្មែរក្រហមទេ។

ដោយសារបញ្ហាតឹងតែងផ្នែកភស្តុភារ និងថវិកានាពេលបច្ចុប្បន្ននេះ ប៉ះពាល់ដល់ពេលវេលាដែលចាំបាច់ដើម្បីរៀបចំសេចក្តីព្រាងចុងក្រោយនៃដីកាដំណោះស្រាយជាភាសាអង់គ្លេស និងភាសាខ្មែរ និងដោយសារគិតដល់សិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវទទួលបានសេចក្តីសម្រេចយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន អំពីលទ្ធផលនៃកិច្ចដំណើរការនីតិវិធីប្រឆាំងជនត្រូវចោទនោះ ទើបពេលឥឡូវនេះ សហចៅក្រមស៊ើបអង្កេត បានសម្រេចចេញដីកាដំណោះស្រាយលើផ្នែកសេចក្តីសម្រេចដោយមានសេចក្តីសង្ខេបអំពីសំអាងហេតុ ហើយឯកសារដាច់ដោយឡែកមួយទៀតដែលមានសំអាងហេតុពេញលេញនឹងដាក់តាមក្រោយក្នុងពេលវេលាសមស្រប។

ការលើកលែងការចោទប្រកាន់នេះក៏មានន័យថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានបដិសេធ។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើរឿងនេះក្នុងថ្ងៃតែមួយផងដែរ។

ដោយសារថាដីកាដំណោះស្រាយមានលក្ខណៈជាការលើកលែងការចោទប្រកាន់ សំអាងហេតុសម្រាប់សេចក្តីសម្រេចនេះ និង ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវរក្សាទុកជាឯកសារសម្ងាត់រហូតដល់ អង្គបុរេជំនុំជម្រះ សម្រេចបដិសេធដីកាលើកលែងការចោទប្រកាន់ និង បញ្ជូនទៅជំនុំជម្រះក្តី។

សហចៅក្រមស៊ើបអង្កេត នឹងរៀបចំ ហើយផ្សព្វផ្សាយសំណៅជាសាធារណៈ នៃសេចក្តីសន្និដ្ឋានផ្លូវច្បាប់សំខាន់ៗពាក់ព័ន្ធបញ្ហាយុត្តាធិការបុគ្គលនៅពេលចេញសេចក្តីសំអាងហេតុពេញលេញ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោកស្រី Hayat Abu-Saleh
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ៩៣៦
អ៊ីមែល៖ abusaleh@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.pheaktra@eccc.gov.kh